ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

ទីស្តីការ
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
Ministry of Posts and Telecommunications
លេខ : ២២៤ មទ.ប្រក

រាជធានី. ភ្នំពេញ ថ្ងៃទី 28 ខែ 11 ឆ្នាំ២០០០

# ប្រកាស

## ស្តីពីការប្រព្រឹត្តទៅនៃមាត់ច្រកទូរគមនាគមន៍អន្តរជាតិ

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- បានឃើញ អនុក្រឹត្យលេខ ៦៦/អនក្រ/បក ចុះថ្ងៃទី ២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- បានឃើញ អនុក្រឹត្យលេខ ០៥អនក្រ ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពី ប្រៃសណីយ៍និងទូរគមនាគមន៍ ។
- យោងតាមសេចក្តីសំរេចអង្គប្រជុំថ្នាក់ដឹកនាំក្រសួងប្រៃសណីយ៍និងទូរគនាគមន៍នាថ្ងៃទី ២១ វិច្ឆិកា ឆ្នាំ ២០០០ ។

## ស ំ រេ ច

**ប្រការ ១ បទបញ្ញត្តិទូទៅ**

ប្រកាសនេះមានគោលបំណងម្យ៉ាងកំណត់លក្ខ័ណ្ឌក្នុងកិច្ចប្រតិបត្តិការ និងការប្រព្រឹត្តទៅនៃបណ្តាញនិងសេវាទូរគមនាគមន៍អន្តរជាតិនិងម្យ៉ាងទៀតមានទំនាក់ទំនងរវាងប្រតិបត្តិករ កំពុងដំណើរការ គឺក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងប្រតិបត្តករមាត់ច្រកអន្តរជាតិថ្មី ។

**ប្រការ ២ : និយមន័យ**

"ប្រតិបត្តិករប្រព័ន្ធមាត់ច្រកអន្តរជាតិ" (Gateway Facilities Operator) មានន័យថា ប្រតិបត្តិករដែលរាជរដ្ឋាភិបាលកម្ពុជាចេញអាជ្ញាប័ណ្ណសំរាប់ ស្ថាបនាបណ្តាញទូរគមនាគមន៍អន្តរជាតិ និងផ្តល់សេវាកម្មអន្តរជាតិចេញ-ចូលព្រះរាជាណាចក្រកម្ពុជា ។

"ប្រតិបត្តិករសេវាមាត់ច្រកអន្តរជាតិ" (Gateway Services Operator) មានន័យថា ប្រតិបត្តិករដែលរាជរដ្ឋាភិបាលកម្ពុជាចេញអាជ្ញាប័ណ្ណសំរាប់ផ្តល់សេវាកម្មអន្តរជាតិមួយចំនួនដោយប្រើបណ្តាញរបស់មាត់ច្រកអន្តរជាតិដែលកំពុងដំណើរការ គឺរបស់ក្រសួងប.ទ. ។

"ប្រតបត្តិករក្នុងប្រទេស" (Local Operator) មានន័យថា ប្រតិបត្តិករដែលមានអាជ្ញាប័ណ្ណចេញដោយរាជរដ្ឋាភិបាលប្រទេសកម្ពុជា សំរាប់ស្ថាបនាបណ្តាញ និងផ្តល់សេវាកម្មទូរគមនាគមន៍ក្នុងប្រទេស រួមមានទូរស័ព្ទអចល័តមានខ្សែ ទូរស័ព្ទអចល័តគ្មានខ្សែ និងទូរស័ព្ទចល័ត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

"អត្រាទូទាត់" (Settlement rate) មានន័យថា អត្រាដែលប្រតិបត្តិករទូរគមនាគមន៍នៅបរទេសត្រូវទូទាត់មកឱ្យប្រតិបត្តិករមាត់ច្រក អន្តរជាតិក្នុងប្រទេសសំរាប់ការបំរើការសន្ទនាអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

"លេខកូដតភ្ជាប់" (Access Code) ជាលេខ ៣ខ្ទង់សំរាប់ចាប់ផ្តើមតភ្ជាប់ទៅនឹងបណ្តាញអន្តរជាតិមួយ ។

"ចំណុចតភ្ជាប់" (Point of Interconnect "POI") ចំណុចដែលប្រព័ន្ធនៃភាគីមួយតភ្ជាប់ទៅនឹងប្រព័ន្ធនៃភាគីមួយទៀតសំរាប់ការផ្ទេរការហៅទូរស័ព្ទពី ប្រព័ន្ធមួយទៅប្រព័ន្ធមួយទៀត ។ ចំណុចតភ្ជាប់គឺស្ថិតនៅក្នុងបមាណីឆ្លងកាត់ជាតិរបស់ក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ។

**ប្រការ ៣ : ការហៅរបស់អតិថិជន**

អតិថិជនអាចហៅទៅអន្តរជាតិបានដោយគ្រាន់តែចុចលេខកូដតភ្ជាប់ ០០១ ឬ ០០៧ ដែលពុំអាចជំនួសបានដោយប្រតិបត្តិករណាមួយឡើយ ។

ប្រតិបត្តករមាត់ច្រកអន្តរជាតិអាចបដិសេធមិនផ្តល់សេវាជូនចំពោះអតិថិជនបានដូចជាអ្នកជំពាក់បំណុលសេវាកម្ម ។ល ។

## ប្រការ ៤ : ការផ្សព្វផ្សាយ

រាល់ការផ្សព្វផ្សាយពតិមានពានិជ្ជកម្មត្រូវគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ ៥ : ការចេញវិក័យប័ត្រ

ប្រតិបត្តិករមាត់ច្រកអន្តរជាតិអាចចេញវិក័យប័ត្រទៅឱ្យអតិថិជនផ្ទាល់ឬតាមរយៈប្រតិបត្តិករក្នុងប្រទេស ។ ក្នុងករណីដែលប្រតិបត្តិករចេញវិក័យប័ត្រដល់អតិថិជនផ្ទាល់ វិធីចេញវិក័យប័ត្រ អត្រាតម្លៃ និងរបៀប វាស់នាទីសន្ទនា ត្រូវឱ្យសមស្របតាមការកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

អ្នកជាវអាចមានសិទ្ធិស៊ីវិក័យប័ត្រលំអិតដែលរាយចំណុចនានានៃការប្រើប្រាស់ផ្ទាល់និងមិនផ្ទាល់ដោយច្បាស់ លាស់ ។ ប្រតិបត្តិករទាំងអស់អាចកំណត់តម្លៃក្នុងការផ្តល់វិក័យប័ត្រលំអិតខាងលើ ទៅអតិថិជនតាមអត្រាមួយដែលមានការព្រមព្រៀងពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាមុន ។

ប្រាក់ជំពាក់ទារពុំបាន និងការទារប្រាក់ជំពាក់ ត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវផ្ទាល់របស់ប្រតិបត្តិករនីមួយៗ ។ ក្នុងករណីដែលចំនួនប្រាក់ទារបានមានការខុសគ្នានឹងចំនួនប្រាក់ចែងក្នុងវិក័យប័ត្រ តួលេខក្នុងវិក័យប័ត្រត្រូវយកមកប្រើសម្រាប់ធ្វើការទូទាត់ដែលត្រូវធ្វើឡើងដោយឆាប់ គឺក្នុងរយៈពេល៤៥ថ្ងៃបន្ទាប់ពីក្រសួងប.ទ.បានចេញសេចក្តីបញ្ជាក់រួច ។

ការប្រមូលប្រាក់ពីអតិថិជនត្រូវមានការត្រួតពិនិត្យជារឿយៗពីសំណាក់ក្រសួងប.ទ.និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។ ការប្រមាណប្រាក់បំណុលទារពុំបានត្រូវកំរិតជាអតិបរមាក្នុងអត្រា តែបី (៣) ភាគរយក្នុងមួយឆ្នាំជាមូលដ្ឋាន ។

## ប្រការ ៦ : អត្រាតម្លៃសេវា (Subscriber tariffs)

ប្រតិបត្តិករមាត់ច្រកអន្តរជាតិអាចកំណត់អត្រាតម្លៃសេវាបានតែក្នុងរង្វង់អត្រាដែលបានកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

## ប្រការ ៧ : ការឧបត្ថម្ភពីសេវាកម្មឯទៀត

តម្លៃសេវាដែលស្នើមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ឱ្យអនុម័ត ត្រូវចែងឱ្យច្បាស់នូវកត្តាតម្លៃ ដោយមិនត្រូវរាប់បញ្ចូលប្រាក់ឧបត្ថម្ភបានមកពីសេវាកម្ម និងអាជីវកម្មឯទៀតរបស់ខ្លួនឡើយ ។ សេវាកម្ម បំរើដោយក្រសួងប.ទ.អាចស្ថិតក្នុងការលើកលែងក្នុងករណីការធ្វើនោះបំរើប្រយោជន៍សាធារណៈ ។

**ប្រការ ៨ : អត្រាទូរទាត់**

៨.១ អត្រាទូរទាត់ដែលចរចារគ្នារវាងប្រតិបត្តិករមាត់ច្រកអន្តរជាតិ និងប្រតិបត្តិករបរទេសត្រូវមានការឯកភាពពី ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មុននឹងអនុវត្តន៍ ។

៨.២ គ្រប់ប្រតិបត្តិករមាត់ច្រកអន្តរជាតិទាំងអស់ក្នុងប្រទេសកម្ពុជាត្រូវអនុវត្តន៍អត្រាទូរទាត់ដូចគ្នាចំពោះ ប្រទេសឬប្រតិបត្តិករនិមួយៗនៅបរទេស ។ ការទូទាត់ដែលស្ថិតនៅក្រៅអត្រាទូរទាត់យល់ព្រមពី ក្រសួងប.ទ. មិនត្រូវបានអនុញ្ញាតិជាដាច់ខាត ។

**ប្រការ ៩ : ចរន្តសេវាចូល-ចេញ**

ចំពោះកិច្ចព្រមព្រៀង ឬទំនាក់ទំនងណាមួយជាមួយប្រតិបត្តិករបរទេស ប្រតិបត្តិករមាត់ច្រកអន្តរជាតិត្រូវបង្កលក្ខណៈធ្វើឱ្យចំណែកនៃចរន្តសេវាហៅចូលទាំងអស់ ពីប្រតិបត្តិករបរទេសនោះ មកប្រព័ន្ធរបស់ខ្លួនស្មើនឹងភាគរយនៃចរន្តសេវាហៅចេញពីប្រព័ន្ធរបស់ខ្លួន ។ ការកំណត់អត្រាសំរាប់រៀងរាល់ ៣ខែត្រូវផ្អែកទៅលើចរន្តសេវាហៅចេញក្នុងរយៈពេល ៣ខែមុន ។

**ប្រការ ១០ : ការដំណើរការប្រព័ន្ធមាត់ច្រកអន្តរជាតិ**

ប្រព័ន្ធដែលដំណើរការដោយស្របច្បាប់មុនថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ ២០០០ ត្រូវហៅថាប្រតិបត្តករនៃប្រព័ន្ធមាត់ច្រកអន្តរជាតិដែលកំពុងដំណើរការ ។

ប្រតិបត្តករប្រព័ន្ធមាត់ច្រកអន្តរជាតិថ្មីៗដែលរដ្ឋាភិបាលបានអនុញ្ញាតត្រូវមានវិញ្ញាបនប័ត្របញ្ជាក់លក្ខណៈបច្ចេកទេសពីក្រសួងប.ទ.។

វិញ្ញាបនប័ត្របញ្ជាក់លក្ខណៈបច្ចេកទេសត្រូវចេញដោយក្រសួងប.ទ.។

និយ័តករត្រូវបញ្ជាក់ភាពត្រឹមត្រូវនៃ លក្ខណៈបច្ចេកទេស ។

**ប្រការ ១១ : វិញ្ញាបនប័ត្របញ្ជាក់លក្ខណៈបច្ចេកទេស**

វិញ្ញាបនប័ត្រលក្ខណៈបច្ចេកទេសត្រូវផ្អែកលើការផ្តល់ទិន្នន័យលំអិតដោយប្រតិបត្តករជូនទៅនិយ័តករ ។ និយ័តករត្រូវផ្តល់លក្ខណៈសម្បត្តិបច្ចេកទេសគ្រប់ទាំងអស់ទៅប្រតិបត្តករ ។

**ប្រការ ១២ : អាជ្ញាប័ណ្ណឱ្យដំណើរការបណ្តោះអាសន្ន**

អាជ្ញាប័ណ្ណឱ្យដំណើរការបណ្ដោះអាសន្ន អាចចេញឱ្យបានដោយមានការឯកភាពពីរដ្ឋមន្ត្រី ប្រសិនបើមានផលប្រយោជន៍សាធារណៈតម្រូវឱ្យមានសេវាកម្មមាត់ច្រកអន្តរជាតិដំណើរការមុនពេលខ្លួនបំពេញ គ្រប់សព្វទូវលក្ខ័ណ្ឌទាំងអស់នោះ ។

**ប្រការ ១៣: លក្ខ័ណ្ឌបែបបទជាមូលដ្ឋាន**

លក្ខ័ណ្ឌបែបបទជាមូលដ្ឋានមាន :

- កំរិតគុណភាពបច្ចេកទេស.
- របាយការណ៏ការសាកល្បងបច្ចេកទេសនៃដំណើរការបណ្ដាញក្នុងរយៈពេល ៣០ថ្ងៃ យ៉ាងតិច.
- របាយការណ៏លំអិតនៃប្រព័ន្ធវិក័យប័ត្រ និងប្រព័ន្ធគ្រប់គ្រងបណ្ដាញ ។
- របាយការណ៏លំអិតនៃប្រព័ន្ធវាស់នាទីសន្ទនា និងការធ្វើឱ្យត្រូវគ្នាជាមួយប្រព័ន្ធក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។
- ផ្ដល់ប្រព័ន្ធបណ្ដាញបរិបថអន្តរជាតិ ។
- កំរិតគុណភាពច្ចេកទេសត្រូវឱ្យស្របតាម :
    - អនុសាសន៏នៃអង្គការ ITU ។
    - កំរិតគុណភាពបច្ចេកទេសរបស់ជាតិ ។

**ប្រការ ១៤ : ការតភ្ជាប់ប្រព័ន្ធជាមួយប្រតិបត្តិករក្នុងប្រទេស**

កិច្ចព្រមព្រៀងស្ដីពីតម្លៃការតភ្ជាប់ប្រព័ន្ធរវាងប្រតិបត្តិករមាត់ច្រកអន្តរជាតិនិងប្រតិបត្តិករក្នុងប្រទេសទាំងអស់ត្រូវធ្វើឡើងដោយមានការចរចាគ្នារវាងប្រតិបត្តិករទាំងនោះ ។ គោលការណ៏នៃការតភ្ជាប់រវាងប្រព័ន្ធត្រូវធ្វើឡើងនិងត្រូវមានការឯកភាពពីនិយ័តករ ។ការផ្លាស់ប្ដូរនៃកិច្ចព្រមព្រៀងខាងលើត្រូវដាក់ជូនទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៏យ៉ាងតិច៦០ថ្ងៃមុនថ្ងៃអនុវត្ត ដើម្បីពិនិត្យ និងសម្រេច ។

**ប្រការ ១៥ : ការកំណត់សិទ្ធរបស់មាត់ច្រកអន្តរជាតិថ្មី**

១៥.១ ចរន្តសេវារវាងមាត់ច្រកអន្តរជាតិថ្មីនឹងប្រព័ន្ធក្នុងប្រទេសត្រូវឆ្លងកាត់តាមប្រព័ន្ធបមាណីទូរស័ព្ទឆ្លង កាត់ជាតិរបស់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៏ជាចាំបាច់ ។មិនអនុញ្ញាតឱ្យមានការតភ្ជាប់ផ្ទាល់ រវាងប្រព័ន្ធមាត់ច្រកអន្តរជាតិទី២និងបមាណីទូរស័ព្ទរបស់ប្រតិបត្តិករក្នុងប្រទេសឡើយ.។ ការបែងចែកចរន្ត សេវាត្រូវធ្វើតាមគំរោងដែលមានការឯកភាពគ្នាដូចមានចែងក្នុងមាត្រានិយាយអំពីចរន្តចេញ-ចូល។

១៥.២ គំរោងការធ្វើឱ្យចរន្តសេវានានាមានសុវត្ថិភាពនិងគំរោងការប្រព័ន្ធបំរុងត្រូវរៀបចំបង្កើតឡើងរវាងប្រព័ន្ធមាត់ច្រកទាំង២ ។ ប្រតិបត្តិករមាត់ច្រកទី១ត្រូវកំណត់ទំរង់នៃប្រព័ន្ធភ្ជាប់នេះ ។ ការចំណាយសំរាប់រៀបចំនិងតម្លើងប្រព័ន្ធតភ្ជាប់នេះត្រូវប្រតិបត្តករមាត់ច្រកអន្តរជាតិទី២ទទួលបន្ទុក ។

១៥.៣ ការផ្តល់សេវាក្រៅពីសេវាទូរស័ព្ទត្រូវមានការអនុញ្ញាតិពីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ជាមុន ។

១៥.៤ សេវា International calling Card, សេវា Prepaid, សេវា Credit Card ហើយនិងសេវា Oversea direct មិនត្រូវស្ថិតក្នុងសិទ្ធរបស់ប្រតិបត្តករ មាត់ច្រកអន្តរជាតិផ្ទាល់ឡើយ ។ សេវាទាំងនេះត្រូវផ្តល់តាមរយៈប្រតិបត្តករក្នុងប្រទេស ។

## ប្រការ ១៦ : ការត្រួតពិនិត្យចរន្តសន្ទនា

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ អាចចុះត្រួតពិនិត្យគ្រប់ពេលវេលានូវបញ្ជីចរន្តសេវាអន្តរជាតិ ។ ពត៌មានបន្តផ្ទាល់ស្តីពីចរន្តសេវា ត្រូវផ្តល់ដល់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងគោលបំណងត្រួតពិនិត្យគ្រប់ពេលវេលា ។

## ប្រការ ១៧ : ការទូទាត់គណនី

សេចក្តីចម្លងឯកសារទូទាត់គណនីទាំងអស់ត្រូវផ្តល់ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្នុងគោលបំណងត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ ។ ជម្លោះស្តីពីឯកសារខាងលើ ត្រូវស្ថិតនៅក្រោមការដោះស្រាយរវាងប្រតិបត្តិករទាំងអស់ និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

## ប្រការ ១៨ : ការចូលពិនិត្យបណ្តាញមាត់ច្រកអន្តរជាតិ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានសិទ្ធិចូលពិនិត្យបណ្តាញមាត់ច្រកអន្តរជាតិនៃប្រតិបត្តិករទាំងអស់គ្រប់ពេលវេលា ។ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវផ្តល់ដំណឹងឱ្យគ្រប់គ្រាន់និងដោយប្រយ័ត្នប្រយែងចំពោះការចុះពិនិត្យតាមមណ្ឌលទាំងនោះ ។

## ប្រការ ១៩ : ទិដ្ឋានការណ៍ស្តីពីដំណើរការបណ្តាញ

របាយការណ៍ស្តីពីដំណើរការបណ្តាញ និងប្រព័ន្ធទូរគមនាគមន៍មាត់ច្រកអន្តរជាតិត្រូវដាក់ជូនក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុង ៣ខែម្តង ។ ការិយាល័យនិយ័តករមានភារៈកិច្ចទាមទារនិងពិនិត្យរបាយការណ៍ដំណើរការបណ្តាញនោះ ។

លក្ខណៈវិនិច្ឆ័យជាមូលដ្ឋានសម្រាប់របាយការណ៍នោះ មាន :

- អត្រាទទួលចម្លើយបាន (Answer Seizure Ratio)
- អត្រាហៅទូរស័ព្ទពុំបាន (Blocking Rate)
- អត្រាការហៅបានសំរេច (Call completion Rate)

- ពេលរង់ចាំ (Holding Time)
- ការប្រើប្រាស់បរិបថ (Circuit utilisation)
- វិធានការណ៍ជួសជុល និងធ្វើឡើងវិញ
- វិធានការណ៍ផ្ទុកចរន្តសន្ទនាក្នុងបរិបថ (Traffic loading measures), និង
- វិធានការណ៍ឯទៀតៗ ដែលកំណត់ដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

**ប្រការ ២០ : ការរអាក់ខានបំរើសេវាកម្ម**

ប្រតិបត្តិករមាត់ច្រកអន្តរជាតិ ត្រូវជូនដំណឹងជាមុន ដល់ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ចំពោះការផ្អាកសេវាកម្មដែលគ្រោងទុក ហើយនិងក្នុងរយៈពេល ២៤ម៉ោង ចំពោះការរអាក់រអួលបណ្តាលមកពីមូលហេតុនានា ។ ក្នុងករណីមានការផ្អាកនេះចរន្តសេវាដែលមាននោះត្រូវផ្ទេរទៅក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

**ប្រការ ២១ : ការផ្តល់ពត៌មានចាំបាច់**

ប្រតិបត្តិករមាត់ច្រកអន្តរជាតិត្រូវទទួលខុសត្រូវក្នុងការ ផ្តល់ពត៌មានចាំបាច់ចំពោះដំណើរការ និងការប្រព្រឹត្តទៅនៃប្រព័ន្ធរបស់ខ្លួនទៅក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នៅពេលណាមានសំណើសុំ ។ ក្នុងករណីដែលពត៌មានពុំបានផ្តល់ ការសរសេរជាលាយល័ក្ខអក្សរស្តីពីមូលហេតុនេះត្រូវដាក់ជូនរដ្ឋមន្ត្រី ។

**ប្រការ ២២ : ទោសពិន័យ**

ប្រតិបត្តិករប្រព័ន្ធមាត់ច្រកអន្តរជាតិណាដែលក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍រកឃើញថាបានបំរើសេវាកម្ម មិនសមស្រប ក្នុងរបៀបរំលោភខ្លឹមសារនៃអាជ្ញាប័ណ្ណ ឬធ្វើឱ្យខូចខាតប្រយោជន៍ក្រសួងប្រៃសណីយ៍និង ទូរគមនាគមន៍ ឬរាជរដ្ឋាភិបាលកម្ពុជាដោយរាប់បញ្ចូល ការតភ្ជាប់បណ្តាញរបស់ខ្លួនទៅបណ្តាញប្រតិបត្តិករណាដែលគ្មានអាជ្ញាប័ណ្ណ ដោយពុំប្រើចំណុចតភ្ជាប់តាមបមាណីទូរស័ព្ទឆ្លងកាត់ដែលក្រសួង ប.ទ.កំណត់ឱ្យ ឬដោយពុំប្រកាសពីចំណុចតភ្ជាប់, ដោយផ្តល់សេវាកម្មផ្ទុយពីខ្លឹមសារប្រកាសនេះ, ត្រូវទទួលការផ្អាកអាជ្ញាប័ណ្ណ មិនឱ្យដំណើរជាបន្ទាន់ ។ ឧបករណ៍និងគ្រឿងបរិក្ខាប្រព័ន្ធឯទៀតនិងទ្រព្យសំភារៈមានចលនៈទ្រព្យ និងប្រាក់ដែលនៅក្នុងគណនីធនាគារត្រូវរឹបអូសដោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដោយស្របទៅតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា ។ ការពិន័យជាហិរញ្ញវត្ថុ ដែលគិតគូរដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍នឹងត្រូវដាក់បន្ថែមដល់ប្រតិបត្តិករនៅក្នុងករណីរកឃើញការខាតបង់ថវិការបស់ក្រសួង ។ បុគ្គលិកទទួលខុសត្រូវអាចត្រូវប្តឹងទៅតុលាការ ដើម្បីវិនិច្ឆ័យស្របតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២៣** : ប្រតិបត្តករប្រព័ន្ធមាត់ច្រកអន្តរជាតិត្រូវអនុវត្តតាមបទបញ្ញត្តិ USO (Universal Service Obligation) ។

**ប្រការ ២៤** : ប្រតិបត្តិករមាត់ច្រកអន្តរជាតិ និងប្រតិបត្តិករក្នុងប្រទេសទាំងអស់ត្រូវអនុវត្តន៏តាមបទបញ្ញត្តិនៃប្រកាសនេះ ។

**ប្រការ ២៥** : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ២៦** : ប្រកាសនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ ២៧** : ប្រកាសនេះអាចត្រូវធ្វើការកែប្រែតាមការចាំបាច់ ។

**ប្រការ ២៨** : ខុទ្ទកាល័យ អធិការដ្ឋាន និងគ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង មានភារៈកិច្ចអនុវត្តន៏តាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

សូ យុន

**កន្លែងទទួល** :

- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ទិស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង

  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៨ "ដើម្បីអនុវត្តន៏"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia
ជាតិ សាសនា ព្រះមហាក្សត្រ
Nation - Religion - King

ទីស្ដីការ

ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
Ministry of Posts and Telecommunications

រាជធានី. ភ្នំពេញ ថ្ងៃទី .28... ខែ ...11......ឆ្នាំ2000

លេខ :228 MPTC

# REGULATION (PRAKAS) ON THE INTERNATIONAL GATEWAY OPERATION

*****

**The Minister of Posts and** Telecommunications having seen :

- The Constitution of Cambodia
- The Decree No នស/រកត/1198 /72 dated November 30, 1998 on the formation of the Royal Government of Cambodia.
- The Decree No 02. នស/94 dated 20 July 1994 on the establishment and conduct of the Council of Ministers.
- The Decree No នស/រកត/ 0196-20 dated 24 January 1996 on the establishment of the Ministry of Posts and Telecommunications.
- The Sub-decree No 66 អនក្រ/បក dated 22 October 1997 on the organisation and conduct of the Ministry of Posts and Telecommunications
- The Sub-Decree no 05 អនក្រ dated 15 March 1987 on the Posts and Telecommunications
- The resolution of the meeting of responsible MPTC staff dated November 21, 2000.

## DECIDES

**ARTICLE 1. General Provision:**

This regulation is designed to set out the requirements for the operation and conduct of international telecommunications facilities and services as well as the guiding relationship between the Incumbent Operator MPTC and the new International Facilities based entrant(s)

**ARTICLE 2. Definitions**

"**Gateway Facilities Operator**" means an operator licensed by the Government of Cambodia to establish international telecommunications facilities and to provide international services to and from the Kingdom of Cambodia.

កាច់ជ្រុងវិថីលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
ទូរស័ព្ទ : 855 - 23.426993 / 426510
ទូរសារ : 855 - 23.426992 / 426011

Corner street 13 and 102 Wat Phnom
Section - Daun Penh District P.Penh
Tel : 855 - 23.426993 / 426510
Fax : 855 - 23.426992 / 426011

"**Gateway Services Operator**" Means an operator licensed to provide certain international services using capacity or facilities of the incumbent MPTC gateway facilities operator.

"**Local Operator**" means a party licensed by the Government of Cambodia to provide domestic, telecommunications services including fixed wire-line, fixed wireless and mobile cellular within the Kingdom of Cambodia.

"**Settlement Rate**" means the amount to be paid to the Gateway Operator by the overseas carrier for the termination of international traffic in the Kingdom of Cambodia.

"**Access Code**" means a 3-digit code, which initiates access to an international facility

"**Point of Interconnect**" (**POI**) means a physical point(s) where the system of one Party is connected to the system of the other party for calls to be handed over from one system or another. The prime POI is defined as the MPTC national transit switch.

## ARTICLE 3. Consumers' Access

Subscribers of any Local Operators shall be given access to a Gateway facility by simply dialling the international prefix 001 or 007, which can not be substituted by any operator. The Gateway operators may refuse to offer service to particular consumers, e.g. bad debtors.

## ARTICLE 4. Public notice

Commercial advertisements should conform to the relevant laws of the Kingdom of Cambodia .

## ARTICLE 5. Billing

Gateway Operators shall have the choice of billing for international services, their subscribers directly or via the Local Operators. In cases where an operator bills customers directly, the method of billing and the charging rates and pulse rates used shall conform to standards set by the MPTC.

Subscribers will be given the right to request detailed billing and to have the various direct and indirect charges clearly displayed on the bill. Operators may charge customers for detailed billing services at rates agreed to by the MPTC.

Reconciliation of bad debt and collection of overdue accounts will be the responsibility of individuals operators. In the case of variations between collected amount and billed amount of international calls the billed amount will be used for

settlement of accounts promptly i.e. within 45 days of a statement being issued from the MPTC.

Collection: Collections for outgoing calls shall be subject to regular audit by the MPTC and the Ministry of Economy and Finances. Bad debt provision for accounting purposes and settlement provision shall be limited to a maximum of up to only 3% on an annual basis.

ARTICLE 6. Subscriber Tariffs

The international gateway operator(s) may only set the tariffs within the range set by MPTC.

ARTICLE 7. Cross-subsidy

Pricing of services proposed to the MPTC must be defined on allocated costs and not be subject to cross-subsidisation from other services or business conducted by the operators. Services provided by MPTC may be subject to exemption where it is deemed to be in the public interest to do so.

ARTICLE 8. Settlement Rate

8.1 The accounting rates negotiated by the Gateway Operators with overseas carriers shall require approval for implementation from the MPTC .

8.2 The same accounting rate to a particular country or carrier shall apply to all gateway operators in Cambodia. Settlements outside the approved accounting rates are strictly prohibited.

ARTICLE 9. Incoming and Outgoing Traffic

In respect of any agreements or arrangements entered into with an overseas carrier, the Gateway Operator shall ensure that the agreement or arrangements are made so that that Gateway Operator's share of the total incoming traffic into the Kingdom of Cambodia from the overseas carrier shall be equal to that Gateway Operator's share of the total outgoing traffic from the Kingdom of Cambodia to that overseas carrier using their own link facilities. The setting of the ratio for every 3 months shall be based on the previous 3 months outgoing traffic.

**ARTICLE 10. Operation of Gateway Facilities**

Facilities operational and operating as legal entities before November 1, 2000, are deemed to be the incumbent gateway operator.

New proposed gateway facilities operators, approved by the government, will require a license and a certificate of conformance issued by the MPTC. The license and

certificate of conformance will be issued by the MPTC. The regulator will ensure compliance to the License and certificate of conformance.

**ARTICLE 11. Certificate of conformance**

A certificate of conformance will be based on the submission of technical and operating details to the regulator. The regulator will provide the operator with a detailed listing of all technical specifications and operating and performance criteria.

**ARTICLE 12. Provisional licence**

Provisional license may be issued on approval of the Minister if it is deemed to be in the public interest to have additional gateway services operational before full compliance of all requirements by the new gateway operator.

**ARTICLE 13. Basic requirements**

Basic requirements to satisfy compliance will include:

1. Technical operating standards
2. Technical performance reports on at least thirty days pilot trial operations of the Facilities
3. Detailed submission of the billing system to be used and network management systems
4. Detailed submission of the Traffic metering systems and synchronization with MPTC systems.
5. Routing plan for international circuit utilisation
6. Technical standards will conform to relevant :
   ITU Recommendations
   National Standards/specifications

**ARTICLE 14. Interconnect with Domestic Operators**

Interconnect pricing agreements between the gateway operators and all local operators will be negotiated between the parties. An interconnect guideline shall be established between the parties and approved by the regulator. Changes to established plans will require at least sixty days notice from the date of submission to the MPTC for review and approval.

**ARTICLE 15. Restriction on new Gateway Facility**

15.1 Traffic routing from domestic networks to new gateway facility will only be allowed via the MPTC national transit switches. No direct links will be allowed between any other local operators switching facilities. Assignment of traffic will be determined based on the agreed traffic sharing plan established for incoming and outgoing traffic.

15.2 A traffic routing protection plan and redundancy plan will be required between the incumbent and the new Gateway operator. The incumbent will define the guidelines for the plan. Costs to conform to the plan and for establishing POIs will be the responsibility of the new Gateway Operator.

15.3 The provision of services other than switched voice telephony shall require prior approval from the MPTC on a case by case basis.

15.4 International calling card services and international prepaid services, credit card services as well as overseas direct are not included in the operating rights of the Gateway Facility operators. These services should be provided through the local operators.

**ARTICLE 16. Auditing of Traffic**

International Traffic statements shall be open for examination by the MPTC at ANY time. Live traffic information shall be made available to the MPTC for auditing purposes at all times.

**ARTICLE 17. Account Settlement**

A copy of all settlement records shall be provided to the MPTC for the purpose of auditing and verification. Disputes on the records will be subject to resolution between the operators and the MPTC.

**ARTICLE 18 Access to Gateway Facilities**

MPTC shall have the right of access to the facilities of the gateway operators at any time. Sufficient and prudent advice shall be given for intended site visits.

**ARTICLE 19. Performance Measures:**

Network performance and gateway facility performance reports will be submitted to the MPTC on a quarterly basis. The office of the regulator shall be responsible for enforcing the collection and submission of the performance measures. Basic criteria will include: A/S ratio, Blocking rate, Call Completion Rate, Holding Time, Circuit utilisation, repair and restoration measures, traffic loading measures and any others defined by the MPTC.

**ARTICLE 20. Interruptions in service:**

The gateway operator shall inform the MPTC of any planned interruptions in services and any interruptions for any reason within 24 hours. Redundancy for routing of traffic in the event of disruptions will be provided to the MPTC

**ARTICLE 21. Information requirement**

The gateway operator will be responsible for providing all necessary information on the performance and operation of the facilities to the MPTC as and when requested. In the event information is not provided, written justification of the reasons shall be provided to the Minister. The Minister may take whatever action as deemed necessary to rectify the situation and impose penalties on the offending party.

ARTICLE 22. **Penalty**

Any Gateway Facility operator found offering non compliant services or operating facilities in manner deemed to be in violation of any of the terms of the licence or to the detriment of the MPTC or Royal Government of Cambodia such as but not limited to connecting facilities to un-licensed operators, failing to use authorised Points of Interconnect or not declaring interconnection points, providing services not deemed to be within the regulations, supporting a local or national operator to bypass the incumbent gateway shall be subject to immediate suspension of the license to operate. The facility, all equipment, systems and assets both fixed and monetary including bank accounts, will be subject to seizure by the MPTC subject to the Laws of Cambodia. Additional financial penalties calculated by the MPTC will be imposed in the event that monetary losses can be determined. Responsible personnel may be subject to criminal proceedings under the applicable law of Cambodia.

ARTICLE 23. **Universal Service Obligation (USO)**

The Gateway Facility operators shall comply with the provisions of the USO applicable regulation.

ARTICLE 24. All operators, local and international gateways, shall abide by this regulation.

ARTICLE 25. Any provision of the previous regulations contrary to this regulation shall be void.

ARTICLE 26. This regulation shall take effect from the date of signature.

ARTICLE 27. This regulation may be updated from time to time.

ARTICLE 28. The Director of Cabinet, the Inspection Department, all Departments of the Ministry shall be responsible in executing this Regulation as from the signing date.

THE MINISTER

SO-KHUN

**Copied to:**
- General Secretariat of the Senate
- General Secretariat of National Assembly
- Department of Council of Ministers
- Ministry of Economy and Finances
- Cabinet of Samdech Prime Minister
- Cabinet of the Deputy Prime Minister Sar Kheng
- Same as Article 28 "for execution"
- Official journal
- Files